# ការដោះស្រាយជាមួយលោកិយ

១យហ.២:១៥ កុំឱ្យស្រឡាញ់លោកិយ ឬរបស់អ្វីដែលនៅក្នុងលោកិយនេះឱ្យសោះ បើអ្នក ណាស្រឡាញ់លោកិយ អ្នកនោះ គ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ ។

## ភាពខុសគ្នារវាងបាបនិងលោកិយ

ភ្លាមៗបន្ទាប់ពីយើងថ្វាយខ្លួនហើយ បាបគឺជារឿងទី១ ដែលត្រូវដោះស្រាយបន្ទាប់មកគឺលោកិយ ។ ដោយព្រោះទាំងពីរនេះ កំពុងធ្វើឱ្យជីវិតរបស់យើងស្មោកគ្រោក និងជាទីស្អប់ខ្ពើមនៅចំពោះព្រះជាម្ចាស់ ដូច្នេះយើងត្រូវតែដោះស្រាយ និងកម្ចាត់ចេញជាដាច់ខាត ។ ទោះជាយ៉ាងនេះក្តី ភាពស្មោកគ្រោកនៃទិដ្ឋភាពទាំងពីរនេះ មានភាពខុសពីគ្នា ។ ភាពកខ្វក់របស់បាបគឺកាចសាហាវគ្រោតគ្រាត និងអាក្រក់ជាទីបំផុត ចំណែកឯភាពកខ្វក់របស់លោកិយវិញ គឺជាវប្បធម៌និងរឿងរ៉ាវល្អ១ ដែលមើលទៅគួរជាទីគាប់ភ្នែកដល់មនុស្ស ។

## គោលទៅដែលត្រូវដោះស្រាយជាមួយលោកិយ

តើធ្វើដូចម្តេចឱ្យយើងអាចស្គាល់ នូវគោលដៅដែលកំពុងតកេ្ាតមក្តេប់រយើង ហើយតើអ្វីទៅជាមាត្រដ្ឋានសម្រាប់វាស់ចំណុចទាំងនេះ? ទី១ យើងត្រូវការមើលឃើញថា តើគោលដៅទាំងនេះ វាហួសពីតម្រូវការចាំបាច់នៃជីវិតរបស់យើងឬអត់ ។ យើងអាចនិយាយថា អ្វីណាក៏ដោយដែលហួសពីតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់យើង របស់នោះហើយដែលកំពុងតែក្តោបក្តាប់កន្លែងរបស់ព្រះនិងកំពុងតែកាន់កាប់យើង ដូច្នេះ យើងត្រូវការដោះស្រាយជាមួយរបស់នោះជាបន្ទាន់ ។ ឧទាហរណ៍: សម្លៀកបំពាក់ដែលជាតម្រូវការចាំបាច់នោះ មិនមែនជាលោកិយទេ ប៉ុន្តែប្រសិនបើអ្នកណាម្នាក់ យកចិត្តទុកដាក់ខ្លាំងទៅនឹងសម្លៀកពាក់គ្រឿងតុបតែងកាយ ឬចាយលុយខ្ជះខ្ជាយ ដើម្បីធ្វើខ្លួនឱ្យទាន់សម័យ នោះមានន័យថា ទំហំនៃតម្រូវការចាំបាច់របស់គាត់គឺច្រើនហួសល្បត់ ហើយលទ្ធផលនៃតម្រូវការដែលច្រើនហួសល្បត់ដូចនេះ បានក្លាយទៅជាលោកិយរបស់គាត់ ។

តើមានមាត្រដ្ឋានអ្វី ដែលអាចកម្រិតលើតម្រូវការចាំបាច់ប្រចាំថ្ងៃរបស់យើង ទាក់ទងទៅនឹងមនុស្ស សកម្មភាព និងរបស់របរទាំងនេះបាន? មាត្រដ្ឋាននៃតម្រូវការចាំបាច់នៅក្នុងការរស់នៅរបស់យើងត្រូវតែកំណត់ដោយខ្លួនរបស់យើងផ្ទាល់តាមរយៈការអធិដ្ឋាននិងការស្វែងរកគំនិតរបស់ព្រ(seeking the mind of God) ។ យើងមិនអាចវាស់វែងមាត្រដ្ឋានរបស់យើងដោយយោងទៅតាមមាត្រដ្ឋានឬការទាមទាររបស់អ្នកដទៃដែលស្របទៅតាមទស្សនៈនិងអារម្មណ៍របស់យើងបានទេ ។

## មូលដ្ឋានក្នុងការដោះស្រាយជាមួយលោកិយ

មានកត្តាពីរយ៉ាងដែលធ្វើឱ្យអារម្មណ៍ខាងក្នុងរបស់យើង មានឥទ្ធិពលខ្លាំងចំពោះលោកិយនោះគឺ : សេចក្តីស្រឡាញ់របស់យើងចំពោះព្រះជាម្ចាស់ និងការចម្រើនធំឡើងនៅក្នុងជីវិតផ្នែកវិញ្ញាណរបស់យើង។ ទី១ ពេលដែលសេចក្តីស្រឡាញ់របស់យើងចំពោះព្រះ ធ្វើឱ្យយើងជួបជាមួយព្រះជាពន្លឺ នោះទ្រង់ក៏បំភ្លឺ និង លាតត្រដាងឱ្យយើងមើលឃើញលោកិយ ។ ពេលដែលពន្លឺនេះរះឡើង ពន្លឺនេះបំភ្លឺឱ្យយើងមើលឃើញលោកិយនៅក្នុងយើង។

## ការអនុវត្តដោះស្រាយជាមួយលោកិយ

ពេលដែលយើងខំព្យាយាមដោះស្រាយជាមួយលោកិយ យើងត្រូវតាំងចិត្តយ៉ាងរឹងមាំ ក្នុងការបិទគំនិតទាំង អស់ខាងលោកិយ ។ យើងមិនគួរគ្រាន់តែបិទបង្អួចនេះប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវខ្ទាស់រនុកខាងក្នុង ហើយថែ មទាំងធ្វើឱ្យបង្អួចនេះក្លាយទៅជាជញ្ជាំងផងដែរ ។ បើយើងធ្វើដូច្នេះ យើងពិតជាអាចដោះស្រាយបញ្ហា ជាមួយលោកិយ បានយ៉ាងគ្រប់ជ្រុងជ្រោយ ។

# 437* លះបង់លោកិយដើម្បីព្រះគ្រិស្ត

(អ. 1025)




២. លះបង់លោកិយដើម្បីព្រះគ្រិស្ត មិនត្រូវការអ្វីល្អវិសេស
ទោះមានគ្រប់យ៉ាងក៏មិនឆ្អែតឆ្អន់ មានតែព្រះគ្រិស្តទើបគ្រប់គ្រាន់ ។

៣. លោកនេះធំពិតតែចិត្តខ្ញុំតូច របស់ណាធំមិនអាចប្រដូច
ចិត្តខ្ញុំតូចតែត្រូវការគ្រប់សព្វ មានតែទ្រង់ទេអាចឲ្យស្កប់ ។

៤. ព្រះគ្រិស្តជាបទចម្រៀងមានជ័យ បើគ្មានព្រះគ្រិស្តក៏គ្មានន័យ
ព្រះគ្រិស្តជាឃ្លាំងទ្រព្យអស្ចារ្យក្រៃ សម្រាកក្នុងទ្រង់ផុតទុក្ខភ័យ ។